FEB 2023
# MONTHLY REPORT
VOLUME 14

**Project Activities:**

- 1st Feb: 2nd Joint Coordination Committee Meeting
- 9th Feb: Strings Monthly Meeting with JICA HQ/ Cambodia Office
- 16th Feb: Final CPD workshop hosted by GLO+UHC project, Thailand
- 27th Feb: First Study Session for Developing INSET Plan (Online)

**សកម្មភាពគម្រោង៖**

- ថ្ងៃទី ១ ខែកុម្ភៈ៖ កិច្ចប្រជុំលើកទី ២ របស់គណៈកម្មការសម្របសម្រួល
- ថ្ងៃទី ៩ ខែកុម្ភៈ៖ កិច្ចប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្តាល JICA និង ការិយាល័យ JICA ប្រចាំប្រទេសកម្ពុជា
- ថ្ងៃទី ១៦ ខែកុម្ភៈ៖ សិក្ខាសាលា លើការអភិវឌ្ឍវិជ្ជាជីវៈបន្ត ចុងក្រោយ រៀបចំដោយគម្រោង GLO+UHC នៃប្រទេសថៃ
- ថ្ងៃទី ២៧ ខែកុម្ភៈ៖ វគ្គសិក្សាដំបូងសម្រាប់អភិវឌ្ឍន៍ផែនការ INSET (អនឡាញ)

## 2nd Joint Coordination Committee Meeting (JCC)
## កិច្ចប្រជុំគណៈកម្មការសម្របសម្រួលលើកទី២ (JCC)


H.E. Prof. Mam Bunsocheat and all the participants


Remarks by Ms. OZAWA Maki, JICA HQ

The Ministry of Health (MoH) and the Strings project successfully co-organized the 2nd JCC meeting at the Sokha Phnom Penh Hotel presided over by H.E. Prof. Mam Bunsocheat, Under Secretary of State for Health, the representative of H.E Prof. Eng Huot, Secretary of State and the Project Director. Other notable representatives who also attended, were from MoH, JICA Cambodia Office, JICA Headquarters (HQ) in Japan (via Zoom), Embassy of Japan, Cambodian Council of Nurses (CCN), Cambodian Association of Nurses (CAN), national hospitals, provincial administration health departments, provincial hospitals, and regional training centers in pilot provinces (Battambang & Kampong Cham).

ក្រសួងសុខាភិបាល និងគម្រោង Strings សហការរៀបចំកិច្ចប្រជុំ JCC លើកទី២ ប្រកបដោយជោគជ័យ នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនសុជាតិ អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល តំណាងឲ្យឯកឧត្តមសាស្ត្រាចារ្យ អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជានាយកគម្រោង។ អ្នកចូលរួមសំខាន់ៗផ្សេងទៀត ដែលបានអញ្ជើញមកពីក្រសួងសុខាភិបាល ការិយាល័យ JICA ប្រចាំប្រទេសកម្ពុជា ទីស្នាក់ការកណ្តាល JICA នៅប្រទេសជប៉ុន (តាមរយៈ Zoom) ស្ថានទូតជប៉ុន គណៈគិលានុបដ្ឋាកកម្ពុជា (CCN) សមាគមគិលានុបដ្ឋាកកម្ពុជា (CAN) មន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលរដ្ឋបាលខេត្ត មន្ទីរពេទ្យខេត្ត និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ នៃខេត្តបាត់ដំបង និងកំពង់ចាម។

At the meeting, the progress of project activities (July-December, 2022) was reported. The approval of the National Guidelines on In-Service Training (INSET) for Nurses was highlighted, and it was disseminated for the first time with the occasion. The planned activities for the next six months were also shared and discussed. During the discussion, training topics we should focus on and how to ensure the quality of INSET training providers were actively debated. Above all, the significance of effective INSET development was reconfirmed among the stakeholders.

នៅក្នុងកិច្ចប្រជុំនេះ គឺមានការរាយការណ៍និងចែករំលែកអំពីវឌ្ឍនភាពនៃសកម្មភាពគម្រោង (ខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២២)។ ការអនុម័តលើគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ត្រូវបានគូសបញ្ជាក់ ហើយក៏ត្រូវបានផ្សព្វផ្សាយជាលើកដំបូងជាមួយនឹងឱកាសនេះផងដែរ។ សកម្មភាពដែលបានគ្រោងទុកសម្រាប់រយៈពេលប្រាំមួយខែបន្ទាប់ត្រូវបានចែករំលែក និងពិភាក្សារួមគ្នា។ ក្នុងអំឡុងពេលនៃការពិភាក្សា ប្រធានបទបណ្តុះបណ្តាលដែលយើងគួរតែផ្តោតលើ និងរបៀបធានាគុណភាពនៃអ្នកផ្តល់ការបណ្តុះបណ្តាល INSET ត្រូវបានពិភាក្សាយ៉ាងសកម្ម។ សំខាន់ជាងនេះទៅទៀត សារៈសំខាន់នៃការអភិវឌ្ឍ INSET ប្រកបដោយប្រសិទ្ធភាពត្រូវបានបញ្ជាក់ឡើងវិញក្នុងចំណោមភាគីពាក់ព័ន្ធ។


Progress report by Dr. Hiura Mizue


Dr. Touch Sokneang presented the project overview


Presentation of the summary of INSET guideline by Dr. Sam Sina

## Final CPD workshop hosted by GLO+UHC project, Thailand
## សិក្ខាសាលាចុងក្រោយ ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត រៀបចំដោយគម្រោង GLO+UHC ប្រទេសថៃ






Mr. Hun Sereyvathana presented the CPD future plan in Cambodia



Workshop participants from various countries and organizations

The final CPD workshop "How to Take Action for Future Plan" hosted by the GLO+UHC project in Thailand was held via Zoom. A wide variety of members from many countries including Cambodia, WHO SEARO and WPRO, Australian College of Nursing (ACN), and JICA participated. At the workshop, Mr. Hun Sereyvathana, the Deputy Treasurer of the Cambodia Council of Nurses (CCN) presented the future plan for CPD system development. All the participants shared their own experiences and strategies for an effective CPD system, and discussed ways to move forward together.

សិក្ខាសាលាចុងក្រោយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្រោមប្រធានបទ "How to Take Action for Future Plan" ដែលរៀបចំដោយគម្រោង GLO+UHC នៅប្រទេសថៃ ត្រូវបានធ្វើឡើងតាមរយៈ Zoom ។ សមាជិកជាច្រើននាក់មកពីប្រទេសជាច្រើនរួមមានប្រទេសកម្ពុជា WHO SEARO និង WPRO, Australian College of Nursing (ACN) និង JICA បានចូលរួម។ នៅក្នុងសិក្ខាសាលានេះ លោក ហ៊ុន សេរីវឌ្ឍនា គណៈគិលានុបដ្ឋាកកម្ពុជា (CCN) បានបង្ហាញពីផែនការអនាគតសម្រាប់ការអភិវឌ្ឍប្រព័ន្ធ CPD ។ អ្នកចូលរួមទាំងអស់បានចែករំលែកបទពិសោធន៍ និងយុទ្ធសាស្រ្តផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ប្រព័ន្ធ CPD ប្រកបដោយប្រសិទ្ធភាព ហើយបានពិភាក្សាគ្នាដើម្បីស្វែងរកដំណោះស្រាយដើម្បីដើរទៅមុខទាំងអស់គ្នា។

## 1st Study Session for Developing INSET Plan (Online)
## វគ្គសិក្សាលើកទី ១ សម្រាប់អភិវឌ្ឍន៍ផែនការ INSET ( អនឡាញ )

On 27th Feb, the 1st study session for developing INSET plan was conducted to present the two following topics:

1. An introduction to the national guidelines on in-service training for nurses
2. The results of training need assessment in 2022 by the project.

Dr. Sam Sina welcomed the new Technical Working Group members who haven't participated in the previous JCC meetings and study sessions including Dr. Bun Sriv from HRDD, Ms. Sim Eng from Kampong Cham RTC, Ms. Sith Sophanya from Battambang RTC, Mr. Pronh Somith from CCN, and Mr. Hour Sovannara from CAN.
Mr. Hun Sereyvathana and Ms. Mao Bunny were among the attendees as well.






1st Study Session for Developing INSET Plan, NMCHC

នាថ្ងៃទី ២៧ ខែកុម្ភៈ វគ្គសិក្សាលើកទី ១ សម្រាប់អភិវឌ្ឍន៍ផែនការ INSET ត្រូវបានធ្វើឡើងដើម្បីបង្ហាញប្រធានបទចំនួនពីរដូចខាងក្រោម៖
១) សេចក្តីណែនាំអំពីគោលការណ៍ណែនាំជាតិស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក
២) លទ្ធផលលើការបណ្តុះបណ្តាលនៃការប៉ាន់ប្រមាណតម្រូវការនៅក្នុងឆ្នាំ ២០២២
លោកបណ្ឌិត សំ ស៊ីណា បានស្វាគមន៍សមាជិកក្រុមការងារបច្ចេកទេសថ្មី ដែលមិនបានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការសម្របសម្រួល (JCC) និងវគ្គសិក្សាកន្លងមក រួមមាន លោកវេជ្ជបណ្ឌិត ប៊ុន ស្រ៊ីវ មកពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស លោកស្រី ស៊ឹម អេង មកពីសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម លោកស្រី សិទ្ធ សុផាន់យ៉ា មកពីសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង លោក ប្រុញ សុមិត្ត មកពី គណៈគិលានុបដ្ឋាកកម្ពុជា និងលោក ហួរ សុវណ្ណារ៉ា មកពីសមាគមគិលានុបដ្ឋាកកម្ពុជា។
លោក ហ៊ុន សេរីវឌ្ឍនា និង និងអ្នកស្រី ម៉ៅ ប៊ុន្នី ក៏ស្ថិតក្នុងចំណោមអ្នកចូលរួមផងដែរ។

### UPCOMING ACTIVITIES / សកម្មភាពនាពេលខាងមុខ

- **9th & 10th Mar:** 1st Workshop for the Development of National In-Service Training Plan for Nurses at Kampong Cham
- **ថ្ងៃទី ៩ និង ១០ ខែមីនា៖** សិក្ខាសាលាលើកទី១ លើការអភិវឌ្ឍន៍ផែនការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក ធ្វើនៅខេត្តកំពង់ចាម

**CONTACT INFORMATION**
**Project Office:**
- **Ministry of Health (MoH)**
Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sankat Beoungkak 2, Tuol Kork District, Phnom Penh, Cambodia
- **National Maternal and Child Health Center (NMCHC)**
N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh, Cambodia

**Email: info@jicastrings.com**

JICA's FB Page

Project's Homepage